អនុម័ត្តនៅក្នុងកិច្ចប្រជុំលើកទី៣៩នៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាននាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៧

# ដំណាក់កាលទាំង១០នៃការអភិវឌ្ឍន៍កម្មវិធីធានារ៉ាប់រងផលិតផលដំណាំថ្នាក់ជាតិ៖ សេចក្តីណែនាំជារួម

**Translated from the 10 Phases in Developing a National Crop Insurance Program: Guide Overview and Farmer-Level Demand for Insurance Survey**

Disclaimer: This is an unofficial translation and provided for reference only.

10 Phases in Developing a National Crop Insurance Program: Guide Overview and Farmer-Level Demand for Insurance Survey, 2016.

To find the original version of the guideline please visit the ASEAN Secretariat website, https://asean.org/ or download at https://asean-crn.org/relevant-asean-guidelines-on-land-use/.

The translation has been produced with the support of the Climate Smart Land Use in ASEAN (CSLU) project, funded by the German Ministry for Economic Cooperation and Development and implemented by the Deutsche Gesellschaft für Internationale Zusammenarbeit (GIZ).

german cooperation
DEUTSCHE ZUSAMMENARBEIT

implemented by:

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

In cooperation with

ASEAN climate resilience network

asean

អនុម័តនៅក្នុងកិច្ចប្រជុំលើកទី៣៩នៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើ អាស៊ាននាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៧

# ដំណាក់កាលទាំង១០នៃការអភិវឌ្ឍន៍កម្មវិធីធានារ៉ាប់រង ផលិតផលដំណាំថ្នាក់ជាតិ៖ សេចក្តីណែនាំជារួម

សៀវភៅមគ្គុទ្ទេសក៍នេះគឺជាកម្រងនៃការណែនាំជាជំហានៗសម្រាប់រដ្ឋាភិបាលយកមកពិចារណាមុនពេលចាប់ផ្តើមអនុវត្តន៍កម្មវិធីធានារ៉ាប់រងផលិតផលដំណាំថ្នាក់ជាតិ ឬ សម្រាប់ប្រើប្រាស់ដើម្បីធ្វើការពិនិត្យឡើងវិញក្នុងការកែលម្អ កម្មវិធីដែល កំពុងតែត្រូវបានអនុវត្តន៍នាពេលបច្ចុប្បន្ន។ **មគ្គុទ្ទេសក៍ជារួមដែលមាន១០ដំណាក់ កាលនេះត្រូវបានបង្កើតឡើងសម្រាប់ព្រឹត្តិការណ៍ផ្លាស់ប្តូរចំណេះដឹងបណ្តាញ ភាពធន់នៃអាកាសធាតុអាស៊ាន(ASEAN-CRN) ស្តីពីគោលនយោបាយប្រកបដោយប្រសិទ្ធភាពក្នុងការលើកកម្ពស់ការធានារ៉ាប់រងអាកាសធាតុផ្នែកកសិកម្មដើម្បីបង្កើនភាពធន់នៅក្នុងតំបន់អាស៊ាន** ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៦-១៨ ខែសីហា ឆ្នាំ ២០១៦ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ។

សេចក្តីណែនាំជារួមនេះត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីគម្រោង G4INDO ដែលទទួលបានការឧបត្ថម្ភថវិកាដោយអង្គការអវកាសជាតិរបស់ប្រទេសហូឡង់។ លោកស្រីLaura Johnson Blair ដែលមានតួនាទីជាអ្នកប្រឹក្សាឯករាជ្យគឺជាអ្នកនិពន្ធឈានមុខនៃការបោះពុម្ពផ្សាយនេះ។ លោក Emilio Hernandez ដែលមកពីអង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ និងលោក Chee Koon Ong ដែលមកពីក្រុមហ៊ុន SwissRe Singapore បានចូលរួមចំណែកជួយក្នុងការរៀបចំបោះពុម្ពផងដែរ។

ព្រឹត្តិការណ៍ផ្លាស់ប្តូរចំណេះដឹង ASEAN-CRN ស្តីពីការធានារ៉ាប់រងអាកាសធាតុកសិកម្មត្រូវបានរៀបចំឡើងដោយគម្រោង Deutsche Gesellschaft für Internationale Zusam-menarbeit  (GIZ) GmbH តាមរយៈគម្រោងព្រៃឈើ និងការប្រែប្រួលអាកាសធាតុ (FOR-CC) នៃកម្មវិធី អាស៊ាន-អាល្លឺម៉ង់ស្តីពីការឆ្លើយតបទៅនឹងការប្រែប្រួល អាកាសធាតុ (GAP-CC) និងទទួលបានការឧបត្ថម្ភថវិកាដោយក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍។ ASEAN-CRN ត្រូវបានបង្កើតឡើងដើម្បីធានាថារដ្ឋជាសមាជិកអាស៊ាន (AMS) ស្ថិតនៅក្នុងទីតាំងល្អប្រសើរដើម្បីសម្របសម្រួលដល់វិស័យកសិកម្មរបស់ពួកគេទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ និងការបង្កើនប្រសិទ្ធភាពក្នុងការកាត់បន្ថយ ផលប៉ះពាល់។

## ដំណាក់កាលទី ១. ការវាយតម្លៃបឋមលើអ្នកពាក់ព័ន្ធពហុភាគីស្តីពីតម្រូវការធានារ៉ាប់រងកសិកម្ម

a. ការពិភាក្សាតំណាក់កាលដំបូងនៅក្នុងនាយកដ្ឋានរដ្ឋាភិបាលដែលមានការចាប់អារម្មណ៍លើការធានារ៉ាប់រងកសិកម្ម ដើម្បីកំណត់ពីតម្រូវការសម្រាប់កម្មវិធីបែបនេះ។ ការពិភាក្សាទាំងនេះអាចផ្តោតទៅលើបញ្ហាយុទ្ធសាស្ត្រដើម្បីកាត់បន្ថយហានិភ័យផលប៉ះពាល់អាកាសធាតុ និងកម្មវិធីយុទ្ធសាស្ត្រភាពធន់របស់រដ្ឋាភិបាល ជុំវិញបញ្ហាសម្ពាធអាកាសធាតុ និងផលប៉ះពាល់របស់វា ទៅលើវិស័យកសិកម្មរបស់ប្រទេស ហើយនិងតម្រូវការដើម្បីបង្កើនសេវាកម្មកាត់បន្ថយហានិភ័យជាផ្លូវការចំពោះការផ្តល់ប្រាក់កម្ចីជនបទ។

b. ការចូលរួមរបស់តំណាងវិស័យឯកជនត្រូវបានលើកទឹកចិត្តនៅក្នុងដំណាក់កាលចាប់ផ្តើមជាពិសេសអ្នកដែលនឹងត្រូវបានប៉ះពាល់ដោយផ្ទាល់ឬនឹងបានទទួលអត្ថប្រយោជន៍ពីកម្មវិធីធានារ៉ាប់រងនេះ។ ជាញឹកញាប់ អ្នកតំណាងវិស័យឯកជនបានផ្តល់នូវទស្សនៈផ្សេងៗគ្នាដែលជាលទ្ធផលនឹងធ្វើឱ្យគំរោងកម្មវិធីនេះមានភាពឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ អាចអនុវត្តបានល្អ និងសម្រេចបានលទ្ធផលដែលបានគ្រោងទុក។ លើសពីនេះការចូលរួមពីភាគីពាក់ព័ន្ធឯកជនក្នុងដំណាក់កាលនេះ នឹងមានតម្លៃក្នុងការកំណត់ប៉ារ៉ាម៉ែត្រសម្រាប់ការសិក្សាអំពីលទ្ធភាពដែលអាចធ្វើទៅបាន។

c. ការកំណត់គោលដៅធំទូលាយសម្រាប់ការលើកកម្ពស់ការ ធានារ៉ាប់រងផ្នែកកសិកម្ម និងឧបករណ៍កាត់បន្ថយហានិភ័យជាផ្លូវការ ដែលផ្ទេរហានិភ័យទៅកាន់វិស័យឧស្សាហកម្មធានារ៉ាប់រងឯកជន ឬសាធារណៈ។ ផលិតផលធានារ៉ាប់រងទាំងអស់ នេះអាចបង្កើតការការពារបន្ថែមដើម្បីបំពេញទៅលើនយោបាយនៃការឆ្លើយតប ទៅនឹងការប្រែប្រួលអាកាសធាតុរបស់រដ្ឋាភិបាលនាពេលបច្ចុប្បន្ន ផ្តល់លទ្ធភាពទៅកាន់ការទទួលបានឥណទានជនបទ ឬការផ្តល់ជូនកញ្ចប់នៃ ការឧបត្ថម្ភធន ជាដើម ។

d. បន្ទាប់ពីមានការប្រមូលព័ត៌មានបានទូលំទូលាយហើយ សូមចាប់ផ្តើមក្រុមការងារពហុភាគី។ ក្រុមការងារនេះអាចរួមមានសមាជិកមកពីក្រសួងហិរញ្ញវត្ថុ ក្រសួងកសិកម្ម និយ័តករធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រង នាយកដ្ឋានឧតុ និយមជាតិ ទីប្រឹក្សាបច្ចេកទេស តំណាងអង្គការដឹកនាំកសិករ និងអ្នកពាក់ព័ន្ធដទៃទៀតដូចជាដៃគូអភិវឌ្ឍន៍(ប្រសិនបើរាប់បញ្ចូល) ។

e. ធ្វើការធានាការឲ្យបាននូវការផ្តល់មូលនិធិសម្រាប់ការសិក្សាលើលទ្ធភាពដែលអាចធ្វើបាននិងកម្មវិធីអភិវឌ្ឍន៍។ ប្រភពមូលនិធិដែលល្អបំផុត គឺអាចទទួលបាន មកពីស្ថាប័នខាងក្នុងរបស់រដ្ឋាភិបាលដែលមានក្រសួងហិរញ្ញវត្ថុឬ ក្រសួងកសិកម្ម ឬបើចាំបាច់អាចទទួលបានមកពីដៃគូរអភិវឌ្ឍន៍ផ្សេងៗ។ ទីប្រឹក្សាបច្ចេកទេសខាងក្រៅអាចត្រូវបានជ្រើសយកនៅពេលនេះដើម្បី ត្រួតពិនិត្យ និងធ្វើការពង្រឹងសមត្ថភាពនៅដំណាក់កាលដំបូង សម្រាប់ការសិក្សាអំពីលទ្ធភាពដែលអាចធ្វើបាន ការអភិវឌ្ឍន៍ផលិតផល ការបង្កើតដំណើរការ និងការសាកល្បង។

f. រៀបចំរចនាសម្ព័ន្ធរបាយការណ៍និងការកំណត់ពេលវេលាសម្រាប់ក្រុមការងារ (ដែលអាចរៀបចំដោយយោងតាមសៀវភៅមគ្គុទ្ទេសក៍នេះបាន) ។

## ដំណាក់កាលទី ២. ការសិក្សាលទ្ធភាពនិងការវាយតម្លៃហានិភ័យកសិករ

ការសិក្សាអំពីលទ្ធភាពនេះគឺជាជំហានសំខាន់ក្នុងការអភិវឌ្ឍន៍កម្មវិធីស្រាវជ្រាវនិងបង្កើតប៉ារ៉ាម៉ែត្រសំខាន់ៗសម្រាប់ជាមូលដ្ឋាននៃកម្មវិធី។ការអនុវត្តការប្រមូលទិន្នន័យកម្រិតប្រទេស ហើយនិងការស្ទង់មតិកម្រិតកសិករ អាចត្រូវបានអនុវត្តដោយក្រុមការងារដែលបានចាត់តាំងដោយក្រុមការងារថ្នាក់ជាតិ ឬអ្នកប្រឹក្សាបច្ចេកទេសខាងក្រៅអាចត្រូវបាននាំយកមកដើម្បីផ្តល់ការប្រឹក្សានិងជួយក្នុងការវិភាគទិន្នន័យ។ ក្រុមប្រទេសក្នុងតំបន់ត្រូវបានណែនាំដោយអ្នកជំនាញ ខាងក្រៅ
ដែលអាចចូលរួមក្នុងការពង្រឹងសមត្ថភាពក្រុមការងារថ្នាក់ជាតិដែលនឹងត្រូវចូលរួមនៅក្នុងការអភិវឌ្ឍន៍កម្មវិធីក្នុងដំណាក់កាលទាំង ១០នេះ ។
ការកសាងសមត្ថភាពនិងសមត្ថភាពដោះស្រាយបញ្ហាជាបន្តបន្ទាប់មានសារៈសំខាន់សម្រាប់និរន្តរភាពរយៈពេលវែងនៃកម្មវិធីទាំងនោះ។

a. ***ការប្រមូលទិន្នន័យកម្រិតប្រទេស***
   i. វិស័យកសិកម្ម ឧទាហរណ៍ ខ្សែសង្វាក់តម្លៃដំណាំនិងបសុសត្វសំខាន់ៗ ហានិភ័យសម្រាប់ដំណាំនិងបសុសត្វ
   ii. វិស័យធានារ៉ាប់រង ឧទាហរណ៍ ក្របខ័ណ្ឌបទប្បញ្ញត្តិការធានារ៉ាប់រងកសិកម្មនាពេលបច្ចុប្បន្ន និងផលិតផលកាត់បន្ថយហានិភ័យដែល អាចរកបាន
   iii. វិស័យហិរញ្ញវត្ថុ -ឧទាហរណ៍ ការចូលរួមរបស់រដ្ឋាភិបាលក្នុងការផ្តល់ប្រាក់កម្ចីកសិកម្មនិងជនបទ និងស្ថាប័នហិរញ្ញវត្ថុឯកជនដែលផ្តល់ប្រាក់កម្ចី ដល់កសិករ (នេះអាចរាប់បញ្ចូលទាំងវិស័យក្រៅផ្លូវការ)
   iv. ប្រតិបត្តិករចល័ត - ឧទាហរណ៍ ប្រតិបត្តិករចល័តសំខាន់ៗដែលអាចចូលទៅដល់តំបន់ជនបទបាន
   v. ទិន្នន័យសន្ទស្សន៍ - ឧទាហរណ៍កំណត់ត្រា ទិន្នន័យនៃអាកាសធាតុ  ទិន្នផល និងតម្លៃ
   vi. ការសិក្សាដែលវាយតម្លៃបញ្ហាប្រឈមនៃកម្មវិធីធានារ៉ាប់រងកសិកម្មនាពេលបច្ចុប្បន្ន

b. ***ការស្ទង់មតិកម្រិតកសិករ***– ត្រូវបានអនុវត្តនៅតាមខេត្តនីមួយៗដែលបានជ្រើសរើសដើម្បីអនុវត្តការធានារ៉ាប់រងផ្នែកកសិកម្មហើយវាគួរតែត្រូវបានធ្វើឡើងនៅដំណាក់កាលដំបូងនៃដំណើរការអនុវត្តគំរោង។ ដើម្បីឱ្យល្អ គួរតែមានក្រុមមួយដែលត្រូវបានចាត់តាំងដោយក្រុមការងារ ដើម្បីចូលរួមជាមួយផ្នែកបន្ថែមក្នុងស្រុក (សម្រាប់ការសម្របសម្រួលនិងការធ្វើស្ទង់មតិ) និងគ្រប់គ្រងនៅក្នុងខេត្តនីមួយៗ ឬស្រុកដែលបានជ្រើសរើស ដើម្បីជួប សម្ភាសន៍ ឬអង្កេតក្រុមតំណាងកសិករ។ មុនពេលចាប់ផ្តើមធ្វើការស្ទង់មតិកម្រិតកសិករ ការសង្កត់ធ្ងន់លើការបង្កើតកម្រងសំណួរ និងការពង្រឹងសមត្ថភាពសម្រាប់អ្នកធ្វើការសម្ភាសន៍ គួរតែត្រូវបានធ្វើឡើង។ ប្រធានបទទិន្នន័យខាងក្រោមគួរតែត្រូវបានលើកឡើងនៅក្នុងការស្ទង់មតិនេះ។ នៅក្នុងការស្ទង់មតិជាក់ស្តែង សំណួរនឹងត្រូវបានបកស្រាយខុសគ្នា ហើយឧទាហរណ៍នឹងបានផ្តល់ជូននៅក្នុងកាលៈទេសៈខ្លះៗ។ វាពិតជាសំខាន់ណាស់ដែលអ្នកធ្វើការសម្ភាសន៍ ចាត់ទុកការសម្ភាសន៍នេះ ឱ្យដូចជាការពិភាក្សាសាមញ្ញមួយ សួរសំណួរបន្តដើម្បីដឹងអំពីស្ថានភាពពិតដែលកសិករជួបប្រទះ ដោយមិនមែនគ្រាន់តែសួរសំណួរដូចដែលបានសរសេរនៅក្នុងកំរងសំណួរនោះទេ។ ការស្ទង់មតិនេះស្វែងរកទិន្នន័យដែលមានគុណភាពដើម្បីជាជំនួយដល់ការសម្រេចថាតើការអនុវត្តន៍គំរោងគួរតែផ្អែកលើចំណុចណាមួយ។

i. **គ្រួសារកសិករនិងប្រតិបត្តិការកសិកម្ម** - អាយុ សមាសភាពគ្រួសារ តំបន់ដាំដុះដីដែលជាកម្មសិទ្ធ/ជួល/ប្រវាស់ បំណែងចែកពេលវេលាក្នុងមួយ រដូវកាល ប្រភេទដំណាំដែលបានដាំ ទិន្នផលនៃការប្រមូលផលនាពេលថ្មីៗនេះធៀបនឹងទិន្នផលដែលបានរំពឹងទុក ការប្រែប្រួលតម្លៃ ការផ្តល់ហិរញ្ញប្បទាន/លទ្ធភាពទទួលបានឥណទានសម្រាប់ចំណាយលើវត្ថុធាតុដើមនិងកម្លាំងពលកម្ម ទីផ្សារសម្រាប់ដំណាំដែលបានដាំ និងអន្តរការីផលិតផលវត្ថុធាតុដើមដែលបានប្រើប្រាស់ ហើយនិងប្រភេទ ម៉ាកដែលជាចំណូលចិត្ត និងកន្លែងដែលបានទិញវត្ថុធាតុដើម

ii. **ទម្រង់នៃហានិភ័យនិងការគ្រប់គ្រង -** តើអ្វីជាមូលហេតុចំបង នៃការប្រមូលផលដំណាំមិនបានល្អ (ដែលអាចរួមមាន៖ គ្រោះរាំងស្ងួត ព្យុះភ្លៀងមិនទៀងទាត់ ជំងឺ សត្វល្អិត ការប្រែប្រួលតម្លៃមិនទៀងទាត់ កង្វះខាតទីផ្សារ និងបញ្ហាផ្សេងៗទៀត) តើការបាត់បង់ទិន្នផលនារដូវកាល មុនមានប៉ុន្មានភាគរយ (ប្រសិនបើមាន) ការផ្លាស់ប្ដូរដែលជាបុព្វហេតុ នៃការប្រសើរឡើងនៃទិន្នផលអនុផល តើបច្ចុប្បន្នអ្នកគ្រប់គ្រងហានិភ័យទាំងនេះយ៉ាងដូចម្ដេច ហើយអ្វីខ្លះ ជាយុទ្ធសាស្ត្រទប់ទល់ចំពោះការបាត់បង់នៃការប្រមូលផល ឬផលប៉ះពាល់ លើរដូវដាំដុះបន្ទាប់ទៀត

iii. **ថ្លៃដើមនៃការផលិតកម្ម** - តើអ្នកដាំលើទំហំដីប៉ុន្មានសម្រាប់ដំណាំសំខាន់ មួយ តើអ្នកចំណាយប៉ុន្មានក្នុងរដូវកាលមុនទៅលើ គ្រាប់ពូជ ជី ការរៀបចំដី កម្លាំងពលកម្ម សារធាតុគីមី ការធ្វើស្មៅ ការប្រមូលផល ការបោសសំអាតកាកសំណល់កំទេចកំទី ការដឹកជញ្ជូន និងថ្លៃផ្សេងៗទៀត តើអ្នកទទួលបានប្រាក់សម្រាប់ការចំណាយនេះមកពីណា

iv. **ការធានារ៉ាប់រងដែលអាចទទួលបានពីរដ្ឋាភិបាល**– ហានិភ័យសំខាន់បំផុតដែលត្រូវទទួលបានការធានា តើសំណងនឹងត្រូវបានប្រើយ៉ាងដូចម្ដេច ប្រសិនបើមានការបាត់បង់ក្នុងការប្រមូលផល ប្រសិនបើការវិនិយោគលើកសិដ្ឋានត្រូវបានទទួលការការពារ តើអ្នកនឹងធ្វើអ្វីជាមួយនឹងវត្ថុធាតុដើម/ឥណទាន/ល។ ការយល់ឃើញចំពោះវិធីល្អបំផុតដើម្បីទទួលបានការធានារ៉ាប់រង/សេវាកម្មឬកម្មវិធីបច្ចុប្បន្នដែលកសិករភាគច្រើនកំពុងប្រើប្រាស់។

v. **ការប្រើប្រាស់ទូរសព្ទដៃ** - តើអ្នកប្រើប្រាស់សារSMS, អ៊ិនធឺណិតតាមទូរស័ព្ទញឹកញាប់ប៉ុណ្ណា តើអ្នកបានប្រើប្រាស់ប្រព័ន្ធវេរលុយតាមទូរស័ព្ទ ដែរឬទេ តើក្រុមហ៊ុនដែលផ្ដល់សេវាកម្មមួយណាដែលអ្នកពេញចិត្តឬបានផ្ដល់ប្រព័ន្ធសេវាកម្មដែលបំផុត

vi. **ទស្សនៈនិងបទពិសោធន៍ជាមួយសេវាកម្មធានារ៉ាប់រង**– ផលិតផលធានារ៉ាប់រងបច្ចុប្បន្ននិងអតីតកាល ផលិតផលធានារ៉ាប់រងដែលធ្លាប់មានលក់ក្នុងទីផ្សារពីមុន ប្រភេទនៃធានារ៉ាប់រង (ឧទាហរណ៍ធានារ៉ាប់រងសុខភាព អាយុជីវិត ដំណាំ) ចំណាប់អារម្មណ៍ក្នុងការទទួលយកផលិតផលធានារ៉ាប់រង កង្វល់ដែលមានចំពោះផលិតផលធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងដែលទទួលបានការពេញចិត្ត

vii. **លទ្ធភាពទទួលបានឥណទាន** - តើបច្ចុប្បន្នអ្នកមានបានយកប្រាក់កម្ចី ដែរឬទេ? តើអ្នកមានក្រុមសន្សំតាមភូមិទេ តើអ្នកមានគណនីធនាគារទេ? តើធនាគារផ្ដល់ប្រាក់កម្ចីដល់កសិករសម្រាប់ការចំណាយលើថ្លៃដើមផលិតកម្មឬទេ? តើលក្ខខណ្ឌនៃប្រាក់កម្ចីទាំងនេះមានអ្វីខ្លះ? តើអ្នកធ្លាប់បានទទួលបានកម្ចីពីធនាគារដែរឬទេ? តើមានល័ក្ខខ័ណ្ឌអ្វីខ្លះដើម្បីទទួលបានប្រាក់កម្ចីផ្លូវការនេះ? តើរដ្ឋាភិបាលផ្ដល់ប្រាក់កម្ចីដំណាំដែរឬទេ? តើអ្នកទទួលបានឥណទានប្រាក់កម្ចីពីឈ្មួញឬឈ្មួញកសិកម្មក្នុងស្រុកដែរឬទេ? តើអ្វីទៅជាការប្រាក់លើប្រាក់កម្ចីពីឈ្មួញឬឈ្មួញកសិកម្ម? តើមានអ្វីកើតឡើងប្រសិនបើអ្នកមិនមានលទ្ធភាពសងប្រាក់? តើអ្នកចង់បានប្រាក់កម្ចីបន្ថែមដែរឬទេ? តើអ្នកត្រូវការប្រាក់កម្ចីដើម្បីវិនិយោគលើកសិដ្ឋានឬសម្រាប់គោលបំណងផ្សេងទៀត? តើអ្វីដែលអ្នកនឹងធ្វើខុសគ្នាប្រសិនបើអ្នកអាចខ្ចីប្រាក់បាន?

viii. ***អង្គការកសិករ*** - ការចូលរួមក្នុងអង្គការកសិករក្នុងតំបន់ ការប្រមូលផ្ដុំផ្សេងទៀតនៅក្នុងខេត្ត របៀបដែលអង្គការដំណើរការដោយស្ម័គ្រចិត្តឬជាសមាជិកភាពដែលជាកាតព្វកិច្ច ទំហំនៃអង្គការ អត្ថប្រយោជន៍នៃ សមាជិកភាព (ការចូលប្រើប្រាស់អ្វីដែលអង្គការបានផ្ដល់ជូន ជាដើម )

ix. **គម្រោងរបស់រដ្ឋាភិបាល** - គម្រោងរបស់រដ្ឋាភិបាលបច្ចុប្បន្នដែលផ្តោតលើកសិករក្នុងតំបន់ តើអ្វីដែលជាលទ្ធផលដែលទទួលបាន តម្រូវការដើម្បីទទួលបានអត្ថប្រយោជន៍  និងទស្សនៈអំពីគុណភាពនៃការអនុវត្ត គំរោង

***ការវិភាគលើទិន្នន័យដែលប្រមូលបាននៅកម្រិតកសិករនិងថ្នាក់ជាតិ***
ដើម្បីកំណត់ពីហានិភ័យសំខាន់ៗដែលត្រូវគ្របដណ្តប់ តើផលិតផលអ្វីខ្លះ ដែលអាចធ្វើទៅបាន ដោយផ្អែកលើទិន្នន័យដែលទទួលបាន និងទម្រង់នៃហានិភ័យបណ្តាញចែកចាយដែលមានសក្តានុពល របៀបនៃការទៅជួបកសិករ តម្រូវការប្រាក់ឧបត្ថម្ភ និងការកំណត់ទីតាំង ល្អបំផុតនៅក្នុងរដ្ឋាភិបាល។

## ដំណាក់កាលទី ៣. ភាពជាដៃគូធានារ៉ាប់រងនិងក្របខ័ណ្ឌបទប្បញ្ញត្តិ

a. បើសិនជាមាន សូមពិនិត្យមើលក្របខ័ណ្ឌបទប្បញ្ញត្តិរបស់រដ្ឋាភិបាលទាក់ទង នឹងកសិកម្ម ឬផលិតផលធានារ៉ាប់រងនិងឧបករណ៍ហិរញ្ញវត្ថុដែលមានសំរាប់កសិករខ្នាតតូចនាពេលបច្ចុប្បន្ន។ សន្ទស្សន៍នៃផលិតផលធានារ៉ាប់រង អាចចាត់ចូលជាផ្នែកមួយនៃក្របខ័ណ្ឌបទប្បញ្ញត្តិហិរញ្ញវត្ថុរបស់ប្រទេស។

b. រៀបចំក្របខ័ណ្ឌស្ថាប័នសម្រាប់ការផ្គត់ផ្គង់និងការចែកចាយ ការធានារ៉ាប់រងផ្នែកកសិកម្ម។ ក្របខ័ណ្ឌនេះត្រូវតែរួមបញ្ចូលនូវការយល់ដឹងថាតើការផ្គត់ផ្គង់ធានារ៉ាប់រងនេះនឹងត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនធានារ៉ាប់រងតែមួយ ឬក្រុមហ៊ុនធានារ៉ាប់រងមួយក្រុម។ តើអ្នកណានឹងធានាបន្ថែមចំពោះហានិភ័យ (អ្នកក្នុងស្រុក អន្តរជាតិ ឬទាំងពីរ) និងតួនាទីផ្ទាល់របស់រដ្ឋាភិបាលចំពោះការធានារ៉ាប់រង បទបញ្ញត្តិ និងការត្រួតពិនិត្យ ។ ការរៀបចំស្ថាប័នដូចនេះចាំបាច់ត្រូវតែរៀបចំឱ្យបានឆាប់ហើយអាចស្វែងរកការគាំទ្រដោយអ្នកជំនាញអន្តរជាតិតាមរយៈការស្វែងយកបទពិសោធន៍ពីប្រទេសឬតំបន់ផ្សេងៗ។

c. ធ្វើឱ្យមានការចូលរួមរបស់អាជ្ញាធរបទប្បញ្ញត្តិធានារ៉ាប់រងនិងភាគីពាក់ព័ន្ធការធានារ៉ាប់រងក្នុងវិស័យឯកជននៅក្នុងក្រុមការងារដើម្បីពិភាក្សាអំពីការបន្ថែមឬការកែប្រែក្របខ័ណ្ឌបទប្បញ្ញត្តិណាមួយដើម្បីឱ្យការធានារ៉ាប់រង កសិកម្មអាចអនុវត្តទៅបាននៅក្នុងប្រទេសហើយនឹងអាចនាំយក ទីប្រឹក្សាបច្ចេកទេសសម្រាប់ក្របខ័ណ្ឌបទប្បញ្ញត្តិថ្មីនេះផងដែរ។ អនុញ្ញាតឱ្យក្រុមហ៊ុនក្នុងស្រុកនិងអន្តរជាតិរួមទាំងអន្តរការីធានារ៉ាប់រងមានអាជ្ញាប័ណ្ណត្រឹមត្រូវ។ អ្នកពាក់ព័ន្ធវិស័យឯកជនអាចចូលរួមដោយផ្ទាល់នៅក្នុងដំណើរការនេះដើម្បីធានាឱ្យបានថាបទបញ្ញត្តិចុងក្រោយស្តីពីការធានារ៉ាប់រងកសិកម្មនេះគឺជាក្របខ័ណ្ឌដែលមានលទ្ធភាពសម្រាប់ដំណើរការក្នុងរយៈពេលវែងនិងមានការរីកចំរើនជានិរន្តរភាពនៃវិស័យនេះ។

d. ពិនិត្យឡើងវិញនូវក្រុមហ៊ុនធានារ៉ាប់រងនិងភ្នាក់ងារធានារ៉ាប់រងក្នុងស្រុកបច្ចុប្បន្នដែលពាក់ព័ន្ធឬមានចំណាប់អារម្មណ៍លើការធានារ៉ាប់រងកសិកម្ម ស្វែងយល់ពីផលិតផលបច្ចុប្បន្នដែលមាននៅលើទីផ្សារ  និងកំណត់ដៃគូធានា រ៉ាប់រងក្នុងស្រុកដែលល្អបំផុតដែលអាចជាក្រុមហ៊ុនធានារ៉ាប់រងផ្ទាល់របស់ រដ្ឋាភិបាល។

e. វាយតម្លៃក្រុមហ៊ុនធានារ៉ាប់រងដែលមានសក្តានុពលដោយមើលលើសមត្ថភាពរបស់ពួកគេក្នុងការធានាបន្តទៅលើផលិតផលរបស់រដ្ឋាភិបាល ជំនាញបច្ចេកទេសស្តីពីការរៀបចំផលិតផល/ការកំណត់តម្លៃ និងចំណាប់អារម្មណ៍រយៈពេលវែងក្នុងការអភិវឌ្ឍន៍ទីផ្សារធានារ៉ាប់រងកសិកម្មនៅក្នុងប្រទេស

f. ពិភាក្សាជាមួយម្ចាស់ជំនួយដែលមានសក្តានុពលឬដៃគូអភិវឌ្ឍន៍អន្តរជាតិស្តីពីការចូលរួមផ្នែកបច្ចេកទេសរបស់ពួកគេនៅក្នុងការរចនានិងការចាប់ផ្តើមអនុវត្តកម្មវិធីធានារ៉ាប់រងផលិតផលដំណាំនិងលទ្ធភាពដែលពួកគេអាចផ្តល់

ជាជំនួយមូលនិធិសម្រាប់គំរោងនេះ។នេះគឺជាជំហានមួយដែលត្រូវបន្តធ្វើជាប្រចាំ ហើយការទំនាក់ទំនងគួរតែត្រូវបានចាប់ផ្តើមចាប់ពីដំណាក់កាលទី ១។

g. ធានាឱ្យមានតម្លាភាពនិងសមត្ថភាពក្នុងការជ្រើសរើសនកម្មនាយកដ្ឋានរដ្ឋាភិបាល និងដៃគូអនុវត្តឬក្រុមហ៊ុនសំខាន់ៗទាំងអស់

## ដំណាក់កាលទី ៤. ការបង្កើតគោលនយោបាយជាតិនិងជំនួយរដ្ឋាភិបាល

a. កំណត់ស្វែងរកតួនាទីរបស់រដ្ឋាភិបាលនៅក្នុងកម្មវិធីធានារ៉ាប់រងដែល បញ្ចូលទាំងក្រសួងមួយណាជាអ្នកអនុវត្តនាំមុខគេ(ការកែសម្រួលរចនាសម្ព័ន្ធដែលបាន គ្រោងទុកក្នុងដំណាក់កាលទី១) នាយកដ្ឋានណាមួយជាអ្នកពាក់ព័ន្ធ ដោយផ្ទាល់ និងធនធាន (បុគ្គលិកនិងឧបករណ៍) ដែលនឹងត្រូវការ។

b. វាយតម្លៃកម្រិតមួយនៃការធានារ៉ាប់រង-ឬច្រើនកម្រិត -ដែលរាប់ចាប់ពីកម្រិតមីក្រូ (កសិករម្នាក់ៗដែលទទួលបានការធានារ៉ាប់រង) កម្រិតមេសូ (សម្រាប់អង្គការ ក្រុមហ៊ុន កម្មវិធីថ្នាក់ស្រុក) ឬកម្រិតម៉ាក្រូ (គ្របដណ្តប់ទូទាំងប្រទេសឬតំបន់) ។ ការធានារ៉ាប់រងនេះគឺជាផ្នែកមួយនៃយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យអាកាសធាតុដ៏ធំមួយរបស់រដ្ឋាភិបាល។

c. ពិភាក្សាអំពីតម្រូវការនិងលទ្ធភាពដែលអាចទៅរួចនៃប្រាក់ឧបត្ថម្ភកម្រិតខ្ពស់ តើការចំណាយទាំងនេះនឹងត្រូវចំណាយយ៉ាងដូចម្តេច និងតើអ្វីជាយុទ្ធសាស្ត្រ រយៈពេលវែង - តើប្រាក់ឧបត្ថម្ភនឹងថយចុះតាមពេលវេលាដែរឬទេ

d. ជាកាតព្វកិច្ចឬការស្ម័គ្រចិត្ត - តើកសិករជាអ្នកជ្រើសរើសចូលឬចេញពីការ ធានារ៉ាប់រង ឬវាជាកាតព្វកិច្ចចំពោះកសិករទាំងអស់ ឬកសិករទាំងអស់អាច ជ្រើសរើសប្រើសេវាកម្មផ្សេងក្រៅពីរបស់រដ្ឋាភិបាល (អាចត្រូវបានគាំទ្រ ដោយជម្រើស នៃបណ្តាញចែកចាយ) ។

e. សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយថ្នាក់ជាតិថ្មីសម្រាប់កម្មវិធីធានារ៉ាប់រងដែលរួមបញ្ចូលនូវប្រភពនៃកញ្ចប់ថវិការ។អ្នកជំនាញបច្ចេកទេសមកពីខាងក្រៅរបស់ដៃគូអភិវឌ្ឍន៍អាចមានអត្ថប្រយោជន៍នៅក្នុងតំណាក់កាលនេះ ហើយយើងក៏អាចរៀននិងស្វែងយល់ពីក្របខ័ណ្ឌស្រដៀងគ្នានៅក្នុងប្រទេសស្រដៀងៗគ្នាផងដែរ។

f. បង្កើតគម្រោងចំណាយថវិកាសម្រាប់ការសាកល្បងនិងការអនុវត្តឆ្នាំដំបូង ហើយប្រសិនបើមានការឧបត្ថម្ភបន្ត នោះការរៀបចំគម្រោងចំណាយថវិការគួរតែ ធ្វើអោយបានយ៉ាងហោចណាស់៥ឆ្នាំដើម្បីធានាឱ្យបាននូវលទ្ធភាពហិរញ្ញវត្ថុ សម្រាប់ការអនុវត្តគម្រោង។

## ដំណាក់កាលទី ៥. ការអភិវឌ្ឍន៍ផលិតផល ការចែកចាយ និងការកំណត់តម្លៃ

a. ដោយផ្អែកលើការសិក្សាលទ្ធភាពនិងការពិភាក្សាជាមួយដៃគូធានារ៉ាប់រងក្នុងតំបន់ ត្រូវធ្វើការកំណត់ប្រភេទដំណាំគោលដៅសម្រាប់ការធានារ៉ាប់រងក្នុងតំណាក់កាលសាកល្បង និងឆ្នាំដំបូង កំណត់ហានិភ័យដែលមាន ប្រភេទផលិតផល (សំណងធានារ៉ាប់រង សន្ទស្សន៍) និងប្រភពទិន្នន័យសម្រាប់ផលិតផលទាំងនោះ។

I. *ការរចនាផលិតផលបច្ចេកទេស* - សំណងធានារ៉ាប់រង សន្ទស្សន៍ ឬប្រភេទកូនកាត់ (ត្រូវតែមានការយល់ពីគុណសម្បត្តិ គុណវិបត្តិ និងការអនុវត្តរបស់ប្រភេទនីមួយៗ)។

ធានាឱ្យបានថាអ្នកធានា អ្នកធានាបន្ត និងរដ្ឋាភិបាលមានជំនាញក្នុងការស្វែងរកប្រភពទិន្នន័យ អភិវឌ្ឍន៍គំរូសន្ទស្សន៍ កំណត់តម្លៃផលិតផល។

b. ការប្រមូលទិន្នន័យ  (ទិន្នន័យពីអតីតកាលចាប់ពីចំនួន១០-៣០ឆ្នាំ)សម្រាប់ការអភិវឌ្ឍផលិតផលនិងការកំណត់តម្លៃផលិតផល-សមាមាត្រនៃការបាត់បង់ពីអតីតកាលដោយផ្អែកទៅលើហានិភ័យដែលត្រូវបានគ្របដណ្តប់ ទិន្នន័យអាកាសធាតុនិងទិន្នផលសម្រាប់ផលិតផលសន្ទស្សន៍។ សម្រាប់ផលិតផលសន្ទស្សន៍អាកាសធាតុ ការិយាល័យឧតុនិយមជាតិ និងការិយាល័យស្ថិតិជាតិស្តីពីក្រុមការងារត្រូវធានាឱ្យបានថាការទទួលបានទិន្នន័យប្រព្រិត្តទៅដោយរលូន។

c. សម្រេចចិត្តថាតើកសិករណាខ្លះអាចទទួលបានផលិតផលនេះ ហើយប្រសិនបើមានតារាងកំណត់អ្នកណាដែលអាចទទួលបានការឧបត្ថម្ភធនលើផលិតផល។

d. ដោយផ្អែកលើព័ត៌មានលម្អិតអំពីផលិតផល កំណត់តម្លៃផលិតផល សម្រាប់ប្រទេសនៅតាមកម្រិតស្រុកឬអង្គភាពរដ្ឋបាលដែលតូចបំផុត តាមដែលអាចធ្វើទៅបាន។ បុព្វលាភសុទ្ធត្រូវបានផ្អែកលើការគណនា លើទិន្នន័យប្រវត្តិនៃការអនុវត្តរបស់ដំណាំ។ ផ្តល់ជម្រើសអោយច្រើនសម្រាប់ការគ្រប់គ្រងនិងហានិភ័យដោយរៀបរាប់ពីប្រេកង់នៃការទូទាត់ពីអតីតកាលសម្រាប់ តំបន់ដែលបានជ្រើសរើសដូច្នេះអ្នក ធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលនិងស្វែងយល់ថាតើផលិតផលនីមួយៗនឹង ត្រូវសងប៉ុន្មាន។ ទំនងជាត្រូវការជំនាញអន្តរជាតិ (វិស័យសាធារណៈនិងឯកជន) ដើម្បីសាងសង់សមត្ថភាពក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុក។

e. ប្រសិនបើមានការឧបត្ថម្ភធន សូមរៀបរាប់លម្អិតអំពីផលប៉ះពាល់លើអ្វីដែលកសិករនឹងត្រូវបង់ប្រាក់ដោយថវិការផ្ទាល់ខ្លួនឬតាមរយៈកញ្ចប់ផលិតផល។

f. ស៊ើបអង្កេតនិងកំណត់បណ្តាញចែកចាយល្អបំផុតសម្រាប់ការធានារ៉ាប់រង - តើអាចរួមបញ្ចូលជាមួយឥណទានកសិកម្មឬផលិតផលធានារ៉ាប់រងផ្សេងទៀតបានដែរឬទេ?រួមជាមួយកម្មវិធីជំនួយបច្ចុប្បន្នរបស់រដ្ឋាភិបាល តាមរយៈក្រុមកសិករដែលមានស្រាប់ឬផ្សេងទៀត។

g. ស៊ើបអង្កេតអំពីរបៀបប្រើបណ្តាញទូរស័ព្ទចល័តបច្ចុប្បន្ននិងសមត្ថភាពក្នុងការប្រើប្រាស់ការវេរលុយ សម្រាប់ការចុះឈ្មោះរបស់កសិករ ការទូទាត់ប្រាក់ ការទូទាត់សំណង ការធ្វើទីផ្សារនិងការធ្វើបច្ចុប្បន្នភាពតាមរដូវកាល។

h. ធ្វើការវិភាគអត្ថប្រយោជន៍និងការចំណាយដោយផ្អែកលើទស្សនៈរបស់កសិករដោយគិតគូរអំពីលទ្ធផលនៃការធានារ៉ាប់រង អត្ថប្រយោជន៍ផ្សេងៗរបស់រដ្ឋាភិបាលក្នុងរដូវដែលមានការប្រមូលផលបានល្អ ការប្រមូលផលដែលមានការបាត់បង់៥០% និងរដូវកាលដែលមានមហន្តរាយដោយមានការបាត់បង់ទិន្នផលរហូតដល់ ៩០% (ឬកម្រិតនៃការបាត់បង់ដែលចាត់ទុកជាកម្រិតគ្រោះមហន្តរាយនៅក្នុងប្រទេស) ។ កម្រិតការបាត់បង់ដែលអាចកើតមានទាំងនេះ អាចត្រូវបានកំណត់តាមរយៈការគណនាទិន្នន័យជាក់ស្តែងនៅកម្រិតប្រទេសនិង តាមរយៈការពិគ្រោះយោបល់ជាមួយក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកអំពីកម្រិតហានិភ័យដែលពួកគេបានកំណត់។ នៅក្នុងការវិភាគ ការគណនាត្រូវធ្វើឡើងដោយមើលទៅលើចំណូលនៃប្រមូលផលដែលទទួលបានឬរំពឹងថានឹងទទួលបាន ថ្លៃដើមនៃការបង់លើធានារ៉ាប់រងនៅកម្រិតកសិករ (ដែលមានប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាលតិចតួច) ។

## ដំណាក់កាលទី ៦ ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនិងការបង្កើតដំណើរការ

a. ការបែងចែកយ៉ាងច្បាស់លាស់នូវតួនាទីនិងការទទួលខុសត្រូវរបស់ដៃគូនីមួយៗ គណនេយ្យភាពការតម្រង់ការលើកទឹកចិត្តដើម្បីទទួលបានភាពជោគជ័យ។ ការកំណត់ក្របខ័ណ្ឌការគ្រប់គ្រងគម្រោងឱ្យបានច្បាស់លាស់ពិតជាមានសារៈសំខាន់ខ្លាំងណាស់ (ចំណុចនេះត្រូវបានពិភាក្សាក្នុងដំណាក់កាលមុនរួចហើយ)។

b. រៀបចំសេចក្តីព្រាងបទដ្ឋានស្តង់ដារនៃការអនុវត្ត SOPs ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងតំណើរការនៃការអភិវឌ្ឍន៍តំណាក់កាលនីមួយៗខាងក្រោម៖
   I. ការធ្វើទីផ្សារ
   II. ការចែកចាយ
   III. ការចុះឈ្មោះអតិថិជន (ច្បាប់ដើមឬតាមប្រព័ន្ធឌីជីថល)
   IV. ការប្រមូលបុព្វលាភ
   V. ការប្រមូលទិន្នន័យសម្រាប់ការវាយតម្លៃការបាត់បង់
   VI. ការវាយតម្លៃការបាត់បង់នៅកន្លែងដាំដំណាំ (សម្រាប់ការសងសំណង) ឬតាមរយៈទិន្នន័យសន្ទស្សន៍
   VII. ការបែងចែកសំណងដល់កសិករដែលជួបការខាតបង់
   VIII. មតិយោបល់មកពីមូលដ្ឋានលើហានិភ័យ (សម្រាប់ផលិតផលសន្ទស្សន៍)

c. បង្កើតយុទ្ធសាស្ត្រដែលអាចធ្វើទៅបានសម្រាប់ការបណ្តុះបណ្តាលកសិករ ការធ្វើសង្គមភាវូបនីយកម្ម ការអនុវត្តសាកល្បងហើយបន្ទាប់មកបង្កើនទំហំ បន្ថែម។ កំណត់ទ្រង់ទ្រាយអោយដូចជាផែនការអាជីវកម្មដែលមានភាព ប្រសើរឡើងនៃថវិកា (កែលម្អដោយផ្អែកលើដំណាក់កាលមុន) ។

d. រៀបចំឯកសារចាំបាច់ទាំងអស់ដើម្បីគាំទ្រដល់ SOPs ដែលជាឯកសារគោលនយោបាយសម្រាប់កសិករ

## ដំណាក់កាលទី ៧. ការបណ្តុះបណ្តាលការអនុវត្តនៅកន្លែងនិងការធ្វើឱ្យមាននូវការចូលរួមរបស់កសិករ

a. ការបង្កើតឱ្យមាននូវសៀវភៅណែនាំនិងការបណ្តុះបណ្តាលបុគ្គលិកនៅតាមមូលដ្ឋានដែលនឹងធ្វើការបណ្តុះបណ្តាលបន្តសម្រាប់កសិករនិងការលក់។

b. បង្កើតឱ្យមាននូវការចូលរួមក្នុងសង្គម ទំនាក់ទំនង ការធ្វើទីផ្សារ និងសម្ភារៈបណ្តុះបណ្តាលសម្រាប់កសិករ។

c. បង្កើតឋានានុក្រមបណ្តុះបណ្តាលនិងខ្សែសង្វាក់នៃបទបញ្ជាចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់ភូមិដើម្បីធានាឱ្យបាននូវការទំនាក់ទំនងល្អនិងសមត្ថភាពដឹកនាំបុគ្គលិកថ្នាក់ភូមិ។

d. អនុវត្តការបណ្តុះបណ្តាលនិងការតាមដានចំពោះការបណ្តុះបណ្តាលនៅកម្រិតក្រុមកសិករ (ឬក្រុមផ្សេងទៀតដែលបានកំណត់ដោយបណ្តាញចែកចាយធានារ៉ាប់រងដែលត្រូវបានជ្រើសរើស) ។ កត់ត្រាព័ត៌មានលម្អិតអំពីកសិករឬក្រុមដែលបានទទួលការបណ្តុះ បណ្តាលដោយមានជាមួយលេខទំនាក់ទំនងសម្រាប់ការត្រួតពិនិត្យគុណភាព) ។

e. ផ្តល់នូវមធ្យោបាយនៃការផ្ទៀងផ្ទាត់គុណភាពលើការបណ្តុះបណ្តាលដែលបានធ្វើឡើងនិងការស្ទង់មតិជ្រើសរើសកសិករដែលបានទទួលការបណ្តុះបណ្តាលដើម្បីសាកល្បងការយល់ដឹងអំពីមេរៀនដែលត្រូវបានបង្រៀន (អាចធ្វើការស្ទង់មតិតាមទូរស័ព្ទបាន)

## ដំណាក់កាលទី ៨. ការសាកល្បងឬភស្តុតាងនៃការចាប់ផ្តើមនិងការកែលម្អ

a. ប្រសិនបើអាចធ្វើទៅបាន សាកល្បងដំណើរការលើធាតុផ្សំបច្ចេកទេស នៃផលិតផលជាពិសេសជាមួយផលិតផលសន្ទស្សន៍ដើម្បីធានាឱ្យបានថា ធាតុផ្សំទាំងនោះផ្តោតលើហានិភ័យសមស្របបំផុតនិងកំពុងតែកំណត់គោលដៅបានត្រឹមត្រូវ។

b. ធ្វើការអនុវត្តលើដំណើរការដែលបានបង្កើតឡើងតាមរយៈបណ្តាញចែកចាយដែលបានកំណត់ទុក ដំណើរការទាំងនោះរួមមាន៖ ការចុះបញ្ជីកសិករ ការប្រមូលឬការផ្ទេរការធានារ៉ាប់រងទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុក ការបែកខ្ញែកឯកសារគោលនយោបាយ ការទាមទារសំណង ការវាយតម្លៃការខាតបង់ ការផ្ទេរសំណង។

c. ប្រសិនបើមានការឧបត្ថម្ភធន សូមរាយការណ៍ជូនកសិករដែលបានទទួលការធានារ៉ាប់រងនិងផ្តល់ព័ត៌មានលម្អិតផ្សេងៗទៀតទៅអង្គភាពបង់ប្រាក់ឧបត្ថម្ភធនសម្រាប់ការផ្ទេរប្រាក់ឧបត្ថម្ភធនទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុក។

d. សាកល្បងប្រសិទ្ធភាពនៃការប្រើបច្ចេកវិទ្យាថ្មីៗដូចជាទូរស័ព្ទដៃសម្រាប់ការចុះឈ្មោះ ការប្រមូលបុព្វលាភ ឬការទូទាត់សំណង។

## ដំណាក់កាលទី ៩. វិធីសាស្ត្រនៃការកែសម្រួលយុទ្ធសាស្ត្រ ផលិតផល និងការសម្របសម្រួលជាមួយដៃគូសហការ

a. អនុវត្តការត្រួតពិនិត្យនិងវាយតម្លៃលើការសាកល្បងដើម្បីកំណត់ពីបញ្ហាប្រឈមភាពទន់ខ្សោយនៅគ្រប់ជំហាននៃដំណើរការអនុវត្តដូចជាការសម្របសម្រួលជាមួយដៃគូសហការ និងសមត្ថភាពបច្ចេកទេសរបស់ផលិតផល។

b. ធ្វើការសំភាសន៍ជាមួយកសិករពាក់ព័ន្ធ អាជ្ញាធរក្នុងតំបន់និងបុគ្គលិកដែលជាអ្នកអនុវត្តការងារ ដើម្បីស្វែងយល់ពីឧបសគ្គ និងប្រមូលផ្តុំនូវប្រតិកម្មឬមតិយោបល់លើធាតុផ្សំនៃកម្មវិធីដើម្បីធ្វើឱ្យប្រសើរឡើង។

c. ធ្វើបទបង្ហាញនិងពិភាក្សាជាមួយក្រុមការងារថ្នាក់ជាតិដើម្បីធ្វើការផ្លាស់ប្តូរនិងកែលម្អកម្មវិធីដែលបានសាកល្បងមុនពេលបើកដំណើរការផ្លូវការ។ វាជារឿងដ៏ល្អមួយបើសិនជាមានភាពបត់បែននៅក្នុងផ្នែកជាក់លាក់មួយចំនួននៃក្របខ័ណ្ឌគោលនយោបាយទាក់ទងនឹងប្រភេទផលិតផល ហានិភ័យ ឬយុទ្ធសាស្ត្រអនុវត្តដើម្បីអនុញ្ញាតឱ្យមានការកែលម្អនៅក្នុងកម្មវិធី។

d. លម្អិតរបាយការណ៍របស់ក្រុមការងារស្តីពីការកែលំអកម្មវិធីដែលនឹងត្រូវបានចែកចាយបន្តដល់អ្នកពាក់ព័ន្ធទាំងអស់ ដែលក្នុងនោះរួមមានដូចជា មេរៀនសំខាន់ៗ ប្រចាំថ្ងៃ និងរបៀបនៃការឆ្លើយតបចំពោះចំណុចទាំងអស់នេះរបស់រដ្ឋាភិបាល។

## ដំណាក់កាលទី ១០.ការបើកដំណើរការកម្មវិធីពេញលេញនិងក្នុងទំហំធំជាងមុន

a. អនុវត្តកម្មវិធីយុទ្ធសាស្ត្រ និងបទដ្ឋានស្តង់ដារនៃប្រតិបត្តិការ SOPs ជាមួយភាគីពាក់ព័ន្ធដែលត្រូវបានកែសម្រួលរួច។

b. បន្តធ្វើការត្រួតពិនិត្យនិងវាយតម្លៃជាមួយភាគីពាក់ព័ន្ធ កសិករគោលដៅនិងអន្តរការីរដ្ឋាភិបាលផ្សេងៗទៀត ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពផលិតផលជាបន្តបន្ទាប់។

c. ធ្វើសវនកម្មប្រចាំឆ្នាំលើដៃគូសហការ និងដំណើរការទាំងអស់។

d. អភិវឌ្ឍន៍និងកែលម្អយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការធានារ៉ាប់រងនិងលទ្ធភាពនៃការឧបត្ថម្ភធនដើម្បីធានាថាគោលដៅស្នូលនៃការអនុវត្តការធានារ៉ាប់រងកំពុងត្រូវបានសម្រេច។

# ការស្ទាបស្ទង់មតិធានារ៉ាប់រងសម្រាប់តម្រូវការកម្រិតកសិករ

## 1. សនិទានភាព

គោលដៅនៃការស្ទង់មតិកសិករគឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីតម្រូវការនិងការចង់បានពីផលិតផលធានារ៉ាប់រងកសិកម្មសម្រាប់កសិករគោលដៅដែលទទួលផលចុងក្រោយ។ ការស្ទង់មតិនេះធ្វើឡើងក្នុងដំណាក់កាលទី ២ - ការសិក្សាលទ្ធភាព និងការវាយតម្លៃហានិភ័យកសិករ - នៃដំណាក់កាលទាំង ១០ ក្នុងការអភិវឌ្ឍន៍កម្មវិធីធានារ៉ាប់រងដំណាំកសិកម្មថ្នាក់ជាតិ៖ សេចក្តីណែនាំរួម ដែលត្រូវបានបង្កើតឡើងសម្រាប់សន្និសីទ ASEAN-CRN ។ ដំណាក់កាលសិក្សាលទ្ធភាពគឺជាជំហានសំខាន់ក្នុងការអភិវឌ្ឍកម្មវិធីដើម្បីស្រាវជ្រាវនិងបង្កើតប៉ារ៉ាម៉ែត្រសំខាន់ៗសម្រាប់ជាមូលដ្ឋាននៃកម្មវិធី។ តាមរយៈការវិភាគលើទិន្នន័យដែលប្រមូលបាននៅកម្រិតកសិករនិងថ្នាក់ជាតិដែលទទួលបាននៅក្នុងដំណាក់កាលទី២ លទ្ធផលដែលទទួលបាននោះជួយដល់ការកំណត់ហានិភ័យសំខាន់ៗដែលត្រូវគ្របដណ្តប់ក្នុងកញ្ចប់សេវាធានារ៉ាប់រង តើផលិតផលអ្វីខ្លះដែលមានលទ្ធភាពអាចផលិតចេញបានដោយយោងតាមទិន្នន័យដែលមាន និងទម្រង់នៃហានិភ័យបណ្តាញចែកចាយដែលមានសក្តានុពលមធ្យោបាយក្នុងការទំនាក់ទំនងជា មួយកសិករ តម្រូវការសម្រាប់ប្រាក់ឧបត្ថម្ភធននិងសមាសភាពដ៏ល្អបំផុតនៃក្រុម ធានា រ៉ាប់រងដំណាំថ្នាក់ជាតិ។

ការស្ទង់មតិស្រដៀងគ្នានេះដែរត្រូវបានធ្វើឡើងនៅក្នុងខែមីនាឆ្នាំ ២០១៥ នៅក្នុងតំបន់ គម្រោង G4INDO នៅកោះជ្វាខាងកើត។ ដោយសារតែគោលដៅរបស់គំរោង G4INDO គឺដើម្បីគាំទ្រដល់រដ្ឋាភិបាលឥណ្ឌូនេស៊ីនិងក្រសួងកសិកម្មក្នុងការអនុវត្តកម្មវិធីធានារ៉ាប់រងកសិកម្មឱ្យមានភាពជោគជ័យ វាជាការសំខាន់ដែលគំរោងG4INDO មានការយល់ដឹងច្បាស់លាស់និងត្រឹមត្រូវអំពីបញ្ហាប្រឈមនិងហានិភ័យរបស់ផលិតផលធានារ៉ាប់រងកសិកម្មនាពេលបច្ចុប្បន្នដែលប្រជាកសិករកំពុងជួបប្រទះ។នៅពេលមានការយល់ដឹងច្បាស់លាស់ដូច្នេះ ផលិតផលធានារ៉ាប់រងសមស្រប និងល្អប្រសើរអាច នឹងត្រូវបានអភិវឌ្ឍន៍ឡើងនិងចែកចាយ។ ដោយផ្អែកលើវិធីសាស្ត្រនេះ ការស្ទង់មតិនេះប្រាកដថាមានប្រសិទ្ធភាពពេញលេញ ឬមានលក្ខណៈវិទ្យាសាស្ត្រខ្ពស់ទេ។ គោលដៅចំបងគឺដើម្បីសិក្សាស្វែងយល់តាមដែលអាចធ្វើទៅបានអំពីក្រុមតំណាងកសិករទាក់ទងទៅនឹងបទពិសោធន៍និងតម្រូវការរបស់ពួកគេ។

## 2. ការស្ទង់មតិ

កសិករដែលត្រូវសម្ភាសន៍មិនចាំបាច់ទាល់តែមានបទពិសោធន៍ពាក់ព័ន្ធជាមួយកម្មវិធីធានារ៉ាប់រងកសិកម្មពីមុនឡើយ។ ដើម្បីឱ្យកាន់តែល្អប្រសើរ អ្នកផ្តល់សម្ភាសន៍ក៏អាចមើលឃើញដីរបស់កសិករដើម្បីបង្ហាញឱ្យកាន់តែច្បាស់អំពីអ្វីដែលកសិករកំពុងពន្យល់ទោះបីជាបញ្ហានេះអាចមានការពិបាកទាក់ទងផ្នែកភ័ស្តុភារនៅក្នុងតំបន់ខ្លះក៏ដោយ។

ការពិភាក្សាជាមួយកសិករគួរតែផ្តោតសំខាន់លើលទ្ធភាពដើម្បីស្វែងយល់អំពីស្ថានភាពរបស់កសិករ ទម្រង់នៃហានិភ័យ លទ្ធភាពទទួលបានឥណទាន ការប្រើប្រាស់បច្ចេកវិទ្យាទូរស័ព្ទ និងព័ត៌មានលម្អិតផ្សេងៗទៀតដែលសំខាន់សម្រាប់ការបង្កើតកម្មវិធីធានារ៉ាប់រងដំណាំជាតិដែលប្រកបដោយប្រសិទ្ធភាព។ វិធីសាស្ត្រស្ទង់មតិគឺជាការពិភាក្សាក្រៅផ្លូវការជុំវិញប្រធានបទ មួយចំនួនដែលមិនមែនជាការសួរនិងឆ្លើយកំរងសំណួរដែលមិនមានភាពបត់បែនឬគ្រាន់តែជាសំណួរជ្រើសរើសនោះទេ។ការពិភាក្សានេះគួរតែមានភាពរស់រវើករវាងកសិករនិងក្រុមការងារ។ វិធីសាស្ត្រនេះមានប្រសិទ្ធភាពដោយសារតែវាអនុញ្ញាត ឱ្យមាន លំហូរនៃការសន្ទនាបែបធម្មជាតិដែលកសិករអាចពន្យល់លម្អិតអំពីចំណុចផ្សេងៗ។

## 3. កំរងសំណួរស្ទង់មតិ

1. **សេចក្តីផ្តើម**
   a. ការណែនាំខ្លីៗអំពីអ្នកសំភាសន៍
   b. ពន្យល់ពីគោលបំណងនៃការពិភាក្សានេះ
   c. សួរកសិករថាតើគាត់/នាងមានការយល់ព្រមក្នុងការឆ្លើយសំណួរដែរឬទេ

2. **ពត៍មានលំអិតអំពីគ្រួសារនិងការធ្វើកសិកម្មរបស់កសិករ**
   a. ចំនួនសមាជិកគ្រួសារនិងសមាសភាពសមាជិកគ្រួសារ
   b. ផ្ទៃដីដែលកំពុងធ្វើការដាំដុះនិងចំនួនដីកសិកម្មដែលជាកម្មសិទ្ធ
   c. ជាកសិករពេញម៉ោងឬក៏មានការធ្វើការងារដើម្បីរកប្រាក់ចំណូលផ្សេងទៀត។ បើសិនជាមាន តើជាសកម្មភាពអ្វី
   d. តើគាត់ជាម្ចាស់ចម្ការផ្ទាល់ គាត់ជួល ឬគាត់ធ្វើការបង្វាស់គ្នា
   e. ពេលវេលានៃការដាំដុះ រដូវវស្សា រដូវប្រាំង
   f. ទិន្នផលដែលទទួលបានជាមធ្យមក្នុងមួយរដូវកាល (ក្នុងមួយរដូវប្រមូល ផល) តើទិន្នផលកំរិតណាដែលអាចចាត់ទុកជា" ទិន្នផលល្អឬប្រសើរ
   g. ការប្រមូលទិន្នផលរដូវកាលមុន ផ្តោតលើដំណាំស្រូវហើយបើសិនជាមិន ទទួលបានទិន្នផលល្អ តើមកពីហេតុអ្វី
   h. តើគាត់ផ្គត់ផ្គង់ការចំណាយលើថ្លៃដើមនៃការដាំដំណាំយ៉ាងដូចម្តេច៖ រាល់ការចំណាយដោយប្រើប្រាស់លុយផ្ទាល់ខ្លួន ខ្ចីលុយគេ ធ្វើការងារទាំងអស់ដោយប្រើប្រាស់កំលាំងផ្ទាល់ខ្លួននិងសមាជិកគ្រួសារ ។ល។
   i. តើវត្ថុធាតុដើមអ្វីខ្លះត្រូវបានទិញ? គ្រាប់ពូជ ជី ជីគីមី និងផ្សេងៗទៀត
   j. ម៉ាកវត្ថុធាតុដើមដែលគាត់តែងតែទិញគ្រប់រដូវកាល? តើពួកគេទិញមកពីអ្នកណា?
   k. តើអ្នកណាជាអ្នកទិញទិន្នផលកសិកម្ម តើមានការប្រែប្រួលតម្លៃដែរទេ តើវាជាតម្លៃដែលត្រូវបានកំណត់ដោយរដ្ឋាភិបាលឬទេ?
   l. តើមាននរណាម្នាក់មកតំបន់របស់អ្នកដើម្បីប្រមូលទិន្នន័យអំពីទិន្នផលរបស់អ្នក ជាមួយនឹងការស្ទង់មតិដែរទេ?

3. **ការធ្វើបំណែងចែកថ្លៃដើមផលិតកម្ម**
   a. បំពេញតារាងខាងក្រោមស្តីពីថ្លៃដើមផលិតកម្ម។
   b. តើប្រភពថវិកាអ្វីខ្លះដែលត្រូវការដើម្បីទិញវត្ថុធាតុដើមនិងដើម្បីជួលកម្លាំងពលកម្ម ?

| | | |
|---|---|---|
| **ដំណាំ** | | |
| **តំបន់ដាំដុះ** | | |
| **ពេលវេលានៃកាដាំដុះក្នុងរដូវកាល** | | |
| **ពេលវេលានៃការប្រមូលផលក្នុងរដូវកាល** | | |
| **ការចំណាយលើវត្ថុធាតុដើមនិមួយៗ** | **រៀតណាមដុង** | **មតិផ្សេងៗ** |
| **តម្លៃដើម** | | |
| គ្រាប់ពូជ | | |
| ជី ទី១ | | |
| ជី ទី ២ | | |
| ថ្នាំសំលាប់សត្វចង្រៃ | | |
| ថ្នាំសំលាប់ស្មៅ /ផ្សេងៗទៀត | | |
| វត្ថុធាតុដើមផ្សេងៗទៀត | | |
| **តម្លៃនៃវត្ថុធាតុដើមសរុប** | | |
| **កាចំណាយលើកំលាំងពលកម្ម និងផ្សេងៗ** | | |

| | | |
|---|---|---|
| **ការរៀបចំថ្នាលបណ្ដុះ** | | |
| **ការរៀបចំដី** | | |
| **ការស្ទូងកូនដំណាំ** | | |
| **ការស្រោចស្រពទឹក** | | |
| **ការធ្វើស្មៅ** | | |
| **ជីនិងថ្នាំគីមី** | | |
| **ការប្រមូលទិន្នផល** | | |
| **ដំណាក់កាលក្រោយការប្រមូលផល** | | |
| **ការវេចខ្ចប់– ការចំណាយលើសំភារៈវេចខ្ចប់** | | |
| **ការដឹកជញ្ជូនទៅកាន់ទីផ្សារ** | | |
| **កាចំណាយលើកំលាំងពលកម្ម និងផ្សេងៗសរុប** | | |
| **ការចំណាយសរុប** | | |
| **ការចំណាយសរុបលើផ្ទៃដីមួយហិកតា** | | |

## 4. ទម្រង់នៃហានិភ័យ

a. តើអ្វីជាហេតុផលទូទៅដែលធ្វើអោយអ្នកប្រមូលទិន្នផលមិនបានល្អ? ហេតុផលអាចមានដូចជា៖ គ្រោះរាំងស្ងួត ព្យុះ ភ្លៀងមិនទៀងទាត់ ជំងឺ សត្វល្អិត (សត្វល្អិត ជំងឺផ្សិត ... ) សត្វស៊ីឬគាស់បំផ្លាញដំណាំ (កណ្ដុរ ។ល។ ) ការប្រែប្រួលតម្លៃទីផ្សារ កង្វះទីផ្សារ ចោរលួច ព្រិល ទឹកជំនន់ ... ។
   1. ហានិភ័យធំបំផុតចំពោះការប្រមូលទិន្នផលដែលល្អបំផុត
   2. ការបាត់បង់ទិន្នផលដែលបានជួបប្រទះកាលពីរដូវកាលមុននិងឆ្នាំមុនៗ?
   3. ការផ្លាស់ប្ដូរដែលជាមូលហេតុនាំឱ្យមានការផ្លាល់ប្ដូរទិន្នផលល្អប្រសើរឡើង?

b. តើបច្ចុប្បន្នអ្នកគ្រប់គ្រងហានិភ័យនីមួយៗដោយរបៀបណា ឧទាហរណ៍ដូចជាប្រព័ន្ធធារាសាស្ត្រសម្រាប់គ្រោះរាំងស្ងួតឬសារធាតុគីមីសម្រាប់កត្តាចង្រៃ ជាក់លាក់ណាមួយ?

c. បើគ្មានចំណូលពីការប្រមូលផល តើអ្នកនឹងមានប្រាក់ដើម្បីដាំដំណាំនៅរដូវក្រោយទេ? អ្វីដែលអាចធ្វើទៅបានមានដូចជា៖ កាត់បន្ថយចំនួនអាហារដែលបរិភោគជារៀងរាល់ថ្ងៃ ពឹងផ្អែកច្រើនលើជំនួយឧបត្ថម្ភម្ហូបអាហារ ខ្ចីប្រាក់ ពឹងផ្អែកលើជំនួយពីអ្នកដទៃ ផ្អាកអោយក្មេងៗទៅរៀននៅសាលារៀន លក់សត្វចិញ្ចឹម រកប្រាក់ដោយសកម្មភាពផ្សេងៗដែលមិនមែនជាការធ្វើកសិកម្ម

d. បើសិនជាផលិតផលដំណាំរបស់កសិករមិនត្រូវបានធានា តើពួកគេនឹងធ្វើអ្វីខុសប្លែកពីធម្មតា ៖ ជ្រើសរើសគ្រាប់ពូជផ្សេងទៀត ប្រើប្រាស់ជីបន្ថែម រកអ្នកផ្គត់ផ្គង់ផ្សេងទៀត មិនយកឥណទានកម្ចីទៀតទេ ទទួលបានការងារឬប្រាក់ខែតិចពីការងារពលកម្មធម្មតា

## 5. លទ្ធភាពទទួលបានឥណទាន

a. តើអ្នកធ្លាប់បានទទួលបានកម្ចីពីធនាគារសម្រាប់ធ្វើកសិកម្មដែរឬទេ? តើអ្នកមានស្គាល់អ្នកណាផ្សេងទៀតដែលទទួលកម្ចីបែបណឹងដែរឬទេ?

b. តើភូមិរបស់អ្នកមានក្រុមសន្សំតាមភូមិទេ?

c. តើធនាគារ អង្គការក្រៅរដ្ឋាភិបាល ឬកម្មវិធីរដ្ឋាភិបាលណាខ្លះដែលផ្ដល់កម្ចី ដល់កសិករ?

d. តើអ្នកដឹងអំពីអត្រាការប្រាក់លើប្រាក់កម្ចីទាំងនេះដែរទេ? តើវាត្រូវសងទៅវិញនៅក្នុងរដូវតែមួយឬទាល់តែដល់ពេលប្រមូលផល?

e. តើឈ្មួញឬឈ្មួញកសិកមានការផ្ដល់ប្រាក់កម្ចីដូចនេះដល់កសិករទេ? តើឥណទាននេះមានលក្ខណៈយ៉ាងដូចម្ដេច?

f. ប្រសិនបើកសិករមិនមានលទ្ធភាពសងប្រាក់កម្ចីផ្លូវការដូចនេះវិញ តើអ្នកដឹងទេថានឹងមានអ្វីកើតឡើង?

g. ប្រសិនបើអ្នកអាចទទួលបានប្រាក់កម្ចីសម្រាប់ធ្វើកសិកម្ម តើអ្នកចង់បានទេ?

**6. ការប្រើប្រាស់ទូរស័ព្ទដៃ**

a. តើស៊ីមកាតដែលប្រើជាក្រុមហ៊ុនអ្វី?
b. តើអ្នកផ្ញើសារតាមទូរស័ព្ទញឹកញាប់ប៉ុណ្ណា?
c. ប្រើអ៊ីនធឺណិតតាមទូរស័ព្ទឬលុយទូរស័ព្ទ?

**7. ជម្រើសលើការជ្រើសរើសការធានារ៉ាប់រង**

a. តើអ្នកមានផលិតផលធានារ៉ាប់រងទេ? តើអ្នកធ្លាប់មានពីមុនទេ? តើផលិតផលនោះល្អរឺទេ តើពួកគេផ្តល់សំណងដល់អ្នកដូចដែលបានកំណត់ទេ?
b. តើអ្នកមានក្រុមហ៊ុនឬម៉ាកធានារ៉ាប់រងមួយណាដែលអ្នកទុកចិត្តទេ?
c. តើអ្នកធ្លាប់បានលឺពីកម្មវិធីធានារ៉ាប់រងដំណាំរបស់រដ្ឋាភិបាលទេ?
d. ចំពោះកម្មវិធីធានារ៉ាប់រងដំណាំកសិកម្ម តើអ្នកគិតថាអ្វីខ្លះជាហានិភ័យសំខាន់ៗដែលគួរតែត្រូវទទួលការធានារ៉ាប់រង?
e. តើអ្នកគិតថាអ្វីជាមធ្យោបាយល្អបំផុតដើម្បីទទួលបានការធានារ៉ាប់រង - តើមានសេវាកម្មឬកម្មវិធីធានារ៉ាប់រងណានាពេលបច្ចុប្បន្នដែលកសិករភាគច្រើនកំពុងតែប្រើ?

**8. អង្គការកសិករ**

a. អង្គការកសិករ - តើអ្នកជាសមាជិករបស់ក្រុមកសិករណាទេ?
b. តើកសិករនៅតំបន់របស់អ្នកជាកម្មសិទ្ធិរបស់អង្គការណាទេ? តើវាជាការស្ម័គចិត្តឬជាកាតព្វកិច្ច?
c. តើអង្គការមានអត្ថប្រយោជន៍អ្វីខ្លះ?

**សំណើផ្សេងៗទៀតសម្រាប់ការពិចារណានិងការដាក់បញ្ចូលទៅក្នុងការបង្កើតកម្មវិធីធានារ៉ាប់រងជាតិ៖**

1. ទាក់ទងជាមួយការវាយតម្លៃគោលនយោបាយធានារ៉ាប់រងនាពេល បច្ចុប្បន្ន យើងស្នើសុំឱ្យដាក់បញ្ចូលករណីសិក្សាអំពីល័ក្ខខ័ណ្ឌនៃការ ផ្តល់ប្រាក់កម្ចី។
2. មុនពេលការចាប់ផ្តើមកម្មវិធីពេញលេញ ឯកសារណែនាំក៏គួរតែបញ្ចូលនូវការចេញច្បាប់ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធី។ ជាមួយគ្នានោះ កម្មវិធីដែលនឹងត្រូវចាប់ផ្តើមដំណើរការ គួរតែត្រូវបានផ្អែកលើលទ្ធផលនៃការសិក្សាលទ្ធភាពដែលបានធ្វើឡើង។
3. ការបង្កើតឱ្យមាននៃការធ្វើចំណាត់ថ្នាក់ហានិភ័យនិងការបែងចែកប្រភេទនៃអត្រាបុព្វលាភរ៉ាប់រង ដោយសារតែអត្រានិងការគ្របដណ្តប់នៃការទាមទារនឹងអាស្រ័យយ៉ាងខ្លាំងទៅលើប្រភេទហានិភ័យ
4. ស្នើរសុំអោយការផ្តល់សេវាធានារ៉ាប់រងមានលក្ខណៈជាកាតព្វកិច្ចសម្រាប់ប្រភេទដំណាំជាក់លាក់ផ្សេងៗ និងលទ្ធភាពក្នុងការមានជំរើសសម្រាប់កសិករដែលអាចផ្តល់ហិរញ្ញប្បទានដោយខ្លួនឯង។

**